# ដំណឹងអំពីប្រព័ន្ធបញ្ជីព័ត៌មានចាក់ថ្នាំបង្ការជំងឺ សម្រាប់អ្នកជំងឺ និងឪពុកម្តាយក្មេង

ការចាក់ថ្នាំបង្ការជំងឺ ឬ ‘ការចាក់ថ្នាំបង្ការ’ គឺដើម្បីការពារជំងឺធ្ងន់ធ្ងរមួយចំនួន ។ ការធ្វើតេស្តដំបូងដើម្បីរកមើលរកមើលមេរោគរបេង (TB) គឺអាចជួយក្នុងការបានដឹងថាតើអ្នកមានឆ្លងមេរោគរបេង (TB) ដែរឬទេ ហើយការពិនិត្យបែបនេះ គឺជាអ្វីដែលត្រូវធ្វើមុនកុមារចូលរៀន ឬមុនមនុស្សធំចូលធ្វើការ ។ ការតាមដានឲ្យបានជាប់លាប់អំពីប្រវត្តិការចាក់ថ្នាំបង្ការ/ពិនិត្យមេរោគរបេង របស់អ្នក អាចជាការពិបាក ។ ហើយវាកាន់តែពិបាកខ្លាំងទៅទៀត នៅពេលដែលអ្នកបានទទួលការចាក់ថ្នាំបង្ការ/ការពិនិត្យមើលមេរោគរបេង ពីគ្រូពេទ្យផ្សេងៗគ្នា ។ បច្ចុប្បន្ន គ្រូពេទ្យប្រើប្រព័ន្ធកុំព្យូទ័រមានសុវត្ថិភាព ដែលគេហៅថាបញ្ជីចាក់ថ្នាំបង្ការជំងឺ ដើម្បីតាមដានពីការចាក់ថ្នាំបង្ការ និងការពិនិត្យរកមេរោគរបេង របស់អ្នកជំងឺ ។ បើអ្នកប្តូរគ្រូពេទ្យ គ្រូពេទ្យថ្មីរបស់អ្នក អាចបើកមើលបញ្ជីដែលកត់ត្រាស្ថានភាពចាក់ថ្នាំបង្ការ/ពិនិត្យរកមេរោគរបេង របស់អ្នក ។ វាជាសិទ្ធិរបស់អ្នក ក្នុងការកំណត់ថាតើនរណាខ្លះអាចចូលមើលកំណត់ត្រាព័ត៌មានរបស់អ្នក នៅក្នុងបញ្ជីចាក់ថ្នាំបង្ការកាលីហ្វ័រនីញ៉ា (CAIR, California Immunization Registry) ។

## តើបញ្ជីចាក់ថ្នាំបង្ការអាចជួយអ្នកបានដូចម្តេច?

- រក្សាកំណត់ត្រានៃការចាក់ថ្នាំបង្ការ និងការធ្វើតេស្តរកមេរោគរបេង (ធ្វើតេស្តស្បែក/ឆ្លុះសួតដោយកាំរស្មីអ៊ិច) ដើម្បីកុំឲ្យអ្នកខកខាន ឬពិនិត្យច្រើនដងហួសកម្រិត
- ផ្ញើសាររំឭកនៅពេលដែលអ្នក ឬកូនអ្នកត្រូវចាក់ថ្នាំបង្ការ
- ផ្តល់ឲ្យអ្នកនូវសំណៅកំណត់ត្រាការចាក់ថ្នាំបង្ការ/ការពិនិត្យរោគរបេងពីគ្រូពេទ្យរបស់អ្នក
- អាចបង្ហាញភស្តុតាងអំពីការចាក់ថ្នាំបង្ការ/ការពិនិត្យរោគរបេង ដែលត្រូវការសម្រាប់ចូលទារកដ្ឋាន ចូលរៀន ឬចូលធ្វើការកន្លែងថ្មី

## តើបញ្ជីចាក់ថ្នាំបង្ការអាចជួយក្រុមថែទាំសុខភាពរបស់អ្នកដូចម្តេច?

គ្រូពេទ្យ គិលានុបដ្ឋាក ផែនការធានារ៉ាប់រងសុខភាព និងទីភ្នាក់ងារសុខភាពសាធារណៈ ប្រើបញ្ជីចាក់ថ្នាំបង្ការដើម្បី ៖

- ពិនិត្យមើលថាតើអ្នកត្រូវការចាក់ថ្នាំបង្ការ/ការពិនិត្យរោគរបេងមួយណា
- បង្ការជំងឺឆ្លងក្នុងសហគមន៍របស់អ្នក
- រំឭកអ្នកអំពីថ្នាំបង្ការដែលត្រូវចាក់
- ជួយក្នុងការរក្សាកំណត់ត្រា

## តើសាលារៀន ឬកម្មវិធីផ្សេងទៀត អាចចូលមើលបញ្ជីនេះបានដែរឬទេ?

អាចចូលមើលបាន តែអាចមើលបានដោយមានដែនកំណត់ ។ សាលារៀន ទារកដ្ឋាន និងកម្មវិធីផ្សេងៗទៀតដែលមានការអនុញ្ញាតក្រោមច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា អាច ៖

- មើលថាតើការចាក់ថ្នាំបង្ការ/ការពិនិត្យមេរោគរបេងណាដែលកុមារត្រូវការ
- ធានាឲ្យបានថាកុមារបានទទួលការចាក់ថ្នាំបង្ការ/ការពិនិត្យមេរោគរបេងដែលចាំបាច់ទៅតាមភាពតម្រូវមុនចូលទារកដ្ឋាន ឬចូលរៀន

**តើព័ត៌មានអ្វីនៅក្នុងបញ្ជីចាក់ថ្នាំបង្ការដែលអាចឲ្យអ្នកក្រៅបើកមើលបាន?**

- ឈ្មោះអ្នកជម្ងឺ ភេទ ថ្ងៃខែឆ្នាំកំណើត
- ព័ត៌មានតិចតួចសម្រាប់បង្ហាញអត្តសញ្ញាណអ្នកជំងឺ
- ឈ្មោះឪពុកម្តាយ ឬឈ្មោះអាណាព្យាបាលសិស្ស
- ព័ត៌មានលំអិតអំពីការចាក់ថ្នាំបង្ការ/ការពិនិត្យជំងឺរបេង ឬព័ត៌មានលើកលែងផ្នែកវេជ្ជសាស្ត្ររបស់អ្នកជំងឺ

ព័ត៌មានដែលត្រូវដាក់បញ្ចូលក្នុងបញ្ជីនេះ ត្រូវបានគេគ្រប់គ្រងដូចគ្នានឹងព័ត៌មានឯកជនផ្សេងទៀតផ្នែកវេជ្ជសាស្ត្រដែរ ។ ការយកបញ្ជីនេះទៅប្រើក្នុងផ្លូវខុស នឹងត្រូវទទួលទោសទៅតាមច្បាប់ ។ ក្រោមច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា គឺមានតែការិយាល័យគ្រូពេទ្យ ផែនការធានារ៉ាប់រងសុខភាព ឬនាយកដ្ឋានសុខភាពសាធារណៈប៉ុណ្ណោះ ដែលអាចមើលអាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកបាន ។ មន្ត្រីសុខភាព ក៏អាចបើកមើលព័ត៌មាននេះបានដែរ ដើម្បីការពារសុខភាពសាធារណៈ ។

**សិទ្ធិអ្នកជំងឺ និងសិទ្ធិឪពុកម្តាយសិស្ស**

វាជាសិទ្ធិស្របច្បាប់របស់អ្នក ក្នុងការស្នើសុំអ្នកផ្តល់សេវាកម្មរបស់អ្នក ៖

- ឲ្យបង្ការមិនឲ្យអ្នកផ្តល់សេវាកម្មនិងសាលារៀនផ្សេងទៀត បើកមើលព័ត៌មានរបស់អ្នក (ឬកូនអ្នក) ដែលមាននៅក្នុងបញ្ជីនេះ
- មិនឲ្យផ្ញើសារក្រើនរំឭកអ្នកអំពីការណាត់ជួបចាក់ថ្នាំ
- នូវសំណៅព័ត៌មានការចាក់ថ្នាំបង្ការ/ការពិនិត្យមេរោគរបេងរបស់អ្នក ឬកូនរបស់អ្នក
- ថាតើនរណាខ្លះបានបើកមើលព័ត៌មានរបស់អ្នក និងសុំកែតម្រូវព័ត៌មានណាដែលខុស

**មិនតម្រូវឲ្យមានចំណាត់ការអ្វីឡើយ សម្រាប់ជាផ្នែកនៃ CAIR ។ អ្នកផ្តល់សេវាកម្ម CAIR សាលារៀន និងមន្ត្រីសុខភាពផ្សេងទៀត អាចបើកមើលព័ត៌មានរបស់អ្នក ឬព័ត៌មានរបស់កូនអ្នក ដោយស្វ័យប្រវត្តិ ។**

**បើអ្នកចង់ដាក់ដែនកំណត់ថានរណាខ្លះអាចបើកមើលព័ត៌មានរបស់អ្នក ឬព័ត៌មានរបស់កូនអ្នក ៖**

1. សួរអ្នកផ្តល់សេវាកម្មរបស់អ្នក ដើម្បីរកមើលថាតើពួកគេអាចចាក់សោរព័ត៌មានរបស់អ្នកដែលមាននៅក្នុង CAIR បានដែរឬទេ
2. បើពួកគេមិនអាចចាក់សោរបានទេ សូមបំពេញបែបបទស្នើសុំចាក់សោរព័ត៌មាន CAIR របស់ខ្ញុំ (Request to Lock My CAIR Record) នៅឯ **CAIRweb.org/cair-forms** ។
3. បើអ្នកប្តូរចិត្ត សូមបំពេញពាក្យសុំដើម្បីដោះសោរព័ត៌មាន CAIR របស់ខ្ញុំ (Request to Unlock My CAIR Record)
4. ព្រីនពាក្យសុំនេះ រួចផ្ញើរតាមទូរសារទៅកាន់លេខ 1-888-436-8320 ឬផ្ញើតាមអ៊ីម៉េលទៅកាន់ **CAIRHelpDesk@cdph.ca.gov ។**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ការិយាល័យជំនួយរបស់ CAIR តាមលេខ 800-578-7889 ឬអ៊ីម៉េល CAIRHelpDesk@cdph.ca.gov**